កម្មវិធីឧបករណ៍មិនបង្កទំនាស់ និងការយកចិត្តទុកដាក់នឹងទំនាស់

សាវតា

ក្រុមឧបករណ៍មិនបង្កទំនាស់ គឺជាក្រុមការងារមួយដែលបានបង្កើតឡើងតាំងពីឆ្នាំ ២០១៤ ដោយមានការចូលរួមពីគ្រូបណ្តុះបណ្តាលអាជីព និងបុគ្គលិកអង្គការមួយចំនួន និង មានការគាំទ្រពីអង្គការ Bread for the World (BfdW) ដែលជាអ្នកយកចិត្តទុកដាក់ខ្ពស់លើផលជះនៃការងាររបស់អង្គការទៅលើទំនាស់ក្នុងមូលដ្ឋាន។ នៅចន្លោះឆ្នាំ ២០១៤ ដល់ពាក់កណ្តាលឆ្នាំ ២០១៧ មានអង្គការចំនួន ១៥ បានទទួលព័ត៌មាន និងបទបង្ហាញស្តីពីឧបករណ៍មិនបង្កទំនាស់ ហើយក្នុងនោះដែរ មានអង្គការចំនួន ៨ បានចាប់ផ្តើមអនុវត្តដំណើរការទាំងមូលនៃការវាយតម្លៃឧបករណ៍មិនបង្កទំនាស់នៅក្នុងអង្គការរបស់ខ្លួនផ្ទាល់។ ក្រុមការងារឧបករណ៍មិនបង្កទំនាស់ ត្រូវបានបានរៀបចំឡើងជាផ្លូវការដោយអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គសក) ។

ឧបករណ៍មិនបង្កទំនាស់ សមស្របយ៉ាងខ្លាំងនឹងអង្គការ **គសក** ហើយវាគឺជាអភិក្រមការងារមួយក្នុងចំណោមអភិក្រមសំខាន់ៗនៃកម្មវិធីអភិបាលកិច្ចរបស់អង្គការ គសក ឆ្នាំ ២០១៧-២០២១។ អង្គការ គសក នឹងបន្តផ្សព្វផ្សាយឧបករណ៍មិនបង្កទំនាស់ទៅដល់សមាជិករបស់ខ្លួន និងអង្គការដៃគូរបស់អង្គការនំប៉័ងពិភពលោក។

ក្នុងដំណាក់កាលថ្មីនេះ (២០១៧-២០២១) ដោយមានជំនួយពី អង្គការ **គសក** ជាអ្នកជួយរៀបចំ និងសម្របសម្រួល។ ក្រុមការងារឧបករណ៍មិនបង្កទំនាស់ គ្រោងនឹងពង្រីកចំណេះដឹងស្តីពីឧបករណ៍មិនបង្កទំនាស់ឲ្យកាន់តែទូលំទូលាយថែមទៀត ក្នុងសហគមន៍អង្គការមិនមែនរដ្ឋាភិបាល។

គោលដៅ

អង្គការសង្គមស៊ីវិលកម្ពុជា អនុវត្តកម្មវិធីរបស់ខ្លួនដោយមានការយកចិត្តទុកដាក់នឹងទំនាស់ ដោយមិនបង្កឲ្យមានទំនាស់នៅក្នុងសហគមន៍។

គោលបំណង

ត្រឹមឆ្នាំ ២០២០ អង្គការសង្គមស៊ីវិលកម្ពុជា ធ្វើការកែលម្អផែនការគម្រោង ការអនុវត្ត និងប្រព័ន្ធត្រួតពិនិត្យរបស់ខ្លួនដោយបានប្រើប្រាស់ក្របខណ្ឌការងារឧបករណ៍មិនបង្កទំនាស់។

តើអ្វីជាឧបករណ៍មិនបង្កទំនាស់?

ឧបករណ៍មិនបង្កទំនាស់ គឺជាវិធីសាស្ត្រមួយដែលអាចធ្វើការព្យាករណ៍ទុកជាមុន ហើយមានគោលបំណងបង្កើនការយល់ដឹងពីរបៀបដែលជំនួយអាចបង្កើតឲ្យមានជាសកម្មភាពទំនាស់។ ឧបករណ៍មិនបង្កទំនាស់ បង្កើនការអនុវត្តនៃការយកចិត្តទុកដាក់នឹងទំនាស់ក្នុងគោលនយោបាយ និងប្រតិបត្តិការក្នុងការផ្តល់ជំនួយ ក្នុងគោលបំណងកាត់បន្ថយផលជះអវិជ្ជមានជាអប្បរមា និងបង្កើនផលជះវិជ្ជមានជាអតិបរមា។

សារៈប្រយោជន៍នៃឧបករណ៍មិនបង្កទំនាស់

ឧបករណ៍មិនបង្កទំនាស់ នឹងជួយដល់ស្តាប់ន ចូលរួម ដោះស្រាយបាននូវសំណួរសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- តើជំនួយអភិវឌ្ឍ ជំនួយមនុស្សធម៌ ឬ ការងារកសាងសន្តិភាព អាចធ្វើឲ្យស្ថានភាពទំនាស់កាន់តែធ្ងន់ធ្ងរឡើង ឬ កាន់តែថយចុះ តាមរយៈវិធីដែលពួកគេធ្វើការ និងជម្រើសដែលពួកគេបានជ្រើសដោយរបៀបណា?
- តើអ្វីខ្លះជាឥទ្ធិពលសំខាន់ៗ ទៅលើការងារផ្តល់ជំនួយក្នុងបរិបទផ្សេងគ្នា? និង តើអ្វីខ្លះជាឥទ្ធិពលរបស់បរិបទទៅលើការងារផ្តល់ជំនួយ?
- តើអ្វីខ្លះជាវិធីសាស្ត្រអនុវត្តជាក់ស្តែង ដើម្បីបញ្ចូលការយកចិត្តទុកដាក់នឹងទំនាស់ទៅក្នុងការវិភាគបរិបទ និងទៅក្នុងការរៀបចំកម្មវិធី ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ?
- នៅក្នុងការលើកកម្ពស់គណនេយ្យភាព និងការរៀនសូត្រនៅគ្រប់កម្រិតចាប់តាំងពីអ្នកផ្តល់សេវា រហូតដល់សហគមន៍មូលដ្ឋាន និងទៅដល់ការិយាល័យកណ្តាល និងម្ចាស់ជំនួយ តើការយកចិត្តទុកដាក់នឹងទំនាស់ អាចត្រូវបានត្រួពិនិត្យ និង វាយតម្លៃប្រកបដោយប្រសិទ្ធភាពតាមរបៀបណា?

៧ ជំហាននៃដំណើរការឧបករណ៍មិនបង្កទំនាស់



សកម្មភាពសំខាន់ៗរបស់កម្មវិធីឧបករណ៍មិនបង្កទំនាស់នៅកម្ពុជា



ការកំណត់អ្នកចូលរួម និងលក្ខណៈវិនិច្ឆ័យ

- អង្គការដែលមានឆន្ទៈក្នុងការអនុវត្តឧបករណ៍មិនបង្កទំនាស់ក្នុងស្តាប័នរបស់ខ្លួន
    - បុគ្គលិក ២នាក់ មកពីអង្គការមួយ ដែលមានតួនាទីក្នុងក្រុមដឹកនាំស្តាប័ន
    - មានឆន្ទៈខ្ពស់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលពេល ១ វគ្គ
    - រៀបចំសិក្ខាសាលាអនុវត្តនៅស្តាប័នរបស់ខ្លួន
    - ប្រសិនបើជាអង្គការអន្តរជាតិ អ្នកចូលរួមត្រូវមានឆន្ទៈក្នុងការផ្ទេរចំណេះដឹងពីឧបករណ៍មិនបង្កទំនាស់ទៅដល់ស្តាប័ន/អង្គការដៃគូ

- បុគ្គល (Freelance Consultant)
    - ជាគ្រូបណ្តុះបណ្តាលជាបុគ្គល ដែលមានឆន្ទៈធ្វើការសម្របសម្រួលដំណើរការឧបករណ៍មិនបង្កទំនាស់នៅពេលអនាគត ដែលជាផ្នែកមួយនៃក្រុមការងារឧបករណ៍មិនបង្កទំនាស់នៅកម្ពុជា
    - មានឆន្ទៈខ្ពស់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលពេល ១ វគ្គ

អាតិការសំខាន់ៗ

ម៉ូឌុលទី១

1. សាវតា និង មេរៀនទទួលបានពីកម្មវិធីឧបករណ៍មិនបង្កទំនាស់
2. ៧ ជំហាននៃដំណើរការឧបករណ៍មិនបង្កទំនាស់
3. ជំហានទី១៖ ការស្វែងយល់ពីបរិបទនៃទំនាស់
    - កំណត់ **តំបន់ការងារសមស្រប** ៖ ទីតាំងភូមិសាស្ត្រ និងបរិយាកាសសង្គមដែលទាក់ទងនឹងកម្មវិធីផ្តល់ជំនួយរបស់អ្នក
    - កំណត់ថាតើ ក្រុមណាខ្លះដែលមានទំនាក់ទំនងនឹងទំនាស់ ដែលបង្កឲ្យមានហិង្សា ឬ គ្រោះថ្នាក់ និងប្រហែលជាអាចឈានទៅរកអំពើហិង្សា?
    - តើជំនួយរបស់គម្រោងមានទំនាក់ទំនងនឹងបរិបទទំនាស់ដោយរបៀបណា?

4. ជំហានទី២៖ ការវិភាគកត្តាបែកបាក់ និងប្រភពនៃភាពតានតឹងនៅក្នុងបរិបទ
5. ជំហានទី៣៖ ការវិភាគកត្តាផ្សារភ្ជាប់ និងសមត្ថភាពមូលដ្ឋានសម្រាប់ការកសាងសន្តិភានៅក្នុងបរិបទ


ម៉ូឌុលទី២

6. ជំហានទី៤៖ ការស្វែងយល់ពីសេចក្តីលម្អិតសំខាន់ៗនៃអន្តរាគមន៍របស់គម្រោង (Unpack project)
    - វិភាគសេចក្តីលម្អិតនៃកម្មវិធីជំនួយ៖ *ត្រូវចងចាំថា វាមិនមែនកម្មវិធីទាំងមូលដែលបង្កឲ្យមានបញ្ហា។ សេចក្តីលម្អិតតូចៗរបស់កម្មវិធីនោះទេ ដែលជាអ្នកកំណត់ផលជះ។*
7. ជំហានទី៥៖ ការវិភាគផលជះនៃអន្តរាគមន៍របស់គម្រោង/កម្មវិធីទៅលើកត្តាបែកបាក់ និង កត្តាផ្សារភ្ជាប់ តាមរយៈ ការផ្ទេរធនធាន (Resource Transfers) និង សារបង្កប់ន័យក្រមសីលធម៌ (Implicit Ethical Messages)
    - តើការផ្ទេរធនធាន និង សាបង្កប់ន័យក្រមសីលធម៌ របស់កម្មវិធីមានផលជះទៅលើកត្តាបែកបាក់ និងប្រភពនៃភាពតានតឹងយ៉ាងដូម្តេច?
    - តើការផ្ទេរធនធាន និង សាបង្កប់ន័យក្រមសីលធម៌ របស់កម្មវិធីមានផលជះទៅលើកត្តាផ្សារភ្ជាប់ និងសមត្ថភាពមូលដ្ឋានសម្រាប់ការកសាងសន្តិភាពយ៉ាងដូម្តេច?

ម៉ូឌុលទី៣

8. ជំហានទី៦៖ បង្កើតជម្រើសកម្មវិធី
    - ប្រសិនបើធាតុផ្សំមួយនៃកម្មវិធីជំនួយមានផលជះអវិជ្ជមានទៅលើកត្តាបែកបាក់ (ពង្រឹងកត្តាបែកបាក់ និងបង្កើនភាពតានតឹង ឬ...)
    - ប្រសិនបើធាតុផ្សំមួយនៃកម្មវិធីជំនួយមានផលជះអវិជ្ជមានទៅលើកត្តាផ្សារភ្ជាប់ (ធ្វើឲ្យកត្តាផ្សារភ្ជាប់ និងធ្វើឲ្យសមត្ថភាពមូលដ្ឋានកាន់តែខ្សោយចុះ)
    - បន្ទាប់មកបង្កើតជម្រើសឲ្យបានច្រើនបំផុតតាមតែអាចធ្វើទៅបាន ទៅលើរបៀបធ្វើដែលអ្នកចង់បានដើម្បីធ្វើឲ្យកត្តាបែកបាក់ថយចុះ និងពង្រឹងកត្តាផ្សារភ្ជាប់។
9. ជំហានទី៧៖ សាកល្បងជម្រើស និង រៀបចំឡើងវិញនូវអន្តរាគមន៍របស់កម្មវិធី

    សាកល្បងបង្កើតជម្រើស ដោយប្រើប្រាស់បទពិសោធន៍របស់អ្នក/ក្រុមការងាររបស់អ្នក
    - តើអ្វីជាផលជះដែលអាចកើតមានឡើងទៅលើកត្តាបែកបាក់ ឬ ប្រភពនៃភាពតានតឹង?
    - តើអ្វីជាផលជះដែលអាចកើតមានឡើងទៅលើកត្តាផ្សារភ្ជាប់ ឬ សមត្ថភាពមូលដ្ឋានសម្រាប់ការកសាងសន្តិភាព?
    - ប្រើប្រាស់ជម្រើសដែលល្អបំផុត និងសមស្របបំផុតដើម្បីរៀបចំគម្រោងឡើងវិញ
10. ក្របខណ្ឌការងារឧបករណ៍មិនបង្កទំនាស់



សេវាកម្ម និង តម្លៃ

វគ្គបណ្តុះបណ្តាល ឧបករណ៍មិនបង្កទំនាស់	តម្លៃ	រយៈពេល (ថ្ងៃ)	កំណាត់សម្គាល់
វគ្គបណ្តុះបណ្តាលគ្រូបង្គោល	250$	5	តម្លៃ/នាក់
សិក្ខាសាលាអនុវត្ត	1840$	5	តម្លៃ/វគ្គ
បង្វឹក និង ផ្តល់យោបល់	1380$	6	តម្លៃ/វគ្គ

អាហារូបករណ៍

អាហារូបករណ៍ផ្តល់ជូនចំពោះតែអង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូរបស់អង្គការនំប៉័ងពិភពលោក (Bread for the World) ដែលមានទីតាំងក្នុងប្រទេកម្ពុជាតែប៉ុណ្ណោះ។

- អាហារូបករណ៍ផ្តល់ជូន ៥ ស្តាប័ន ក្នុងមួយឆ្នាំ ហើយក្នុងមួយស្តាប័នផ្តល់ជូនសម្រាប់តែបុគ្គលិក ២នាក់តែប៉ុណ្ណោះ
- អាហារូបករណ៍ផ្តល់ជូន រួមមាន៖
    - o វគ្គបណ្តុះបណ្តាលគ្រូបង្គោលរស្តីពីឧបករណ៍មិនបង្កទំនាស់រយៈពេល ៥ថ្ងៃ
    - o សិក្ខាសាលាអនុវត្តរយៈពេល ៥ ថ្ងៃ
    - o ការបង្វឹក និងផ្តល់យោបល់បន្ថែមរយៈពេល ៦ ថ្ងៃ

    សុរបជាទឹកប្រាក់អាហារូបករណ៍រហូតដល់ ៥០០០ដុល្លារអាមេរិក ក្នុងមួយស្តាប័ន

ផែនការបណ្តុះបណ្តាល ឆ្នាំ ២០១៨

ផែនការសកម្មភាព	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
សិក្ខាសាលាផ្សព្វផ្សាយ (4)		1		1		1		1				
វគ្គបណ្តុះបណ្តាលគ្រូបង្គោល (1)										1		
សិក្ខាសាលាអនុវត្ត (7)	1	1	2	1	1	1						
បង្វឹក និង ផ្តល់យោបល់ (7)												

ការដាក់ពាក្យសុំ



ទំនាក់ទំនង

អ្នកស្រី លុយ ធារី

អ្នកសម្របសម្រួលគម្រោងឧបករណ៍មិនបង្កទំនាស់

ទូរស័ព្ទ 012 33 90 27 / 016 65 90 80

អ៊ីម៉ែល theary.luy@ccc-cambodia.org

ការិយាល័យអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

ទូរស័ព្ទ ០២៣ ២១៦ ០០៩

អ៊ីម៉ែល info@ccc-cambodia.org

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៥៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ភ្នំពេញ